ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលខេត្តពោធិ៍សាត់
លេខៈ ៧៦៤០ ...ឥ.ផ.ណ.ក.២៧ ២៨

# សេចក្តីជូនដំណឹង
## ស្តីពី
## ការដាក់ឱ្យដេញថ្លៃភាសុីគ្រប់ប្រភេទ សម្រាប់ធ្វើអាជីវកម្មឆ្នាំ២០២៥ ទូទាំងខេត្តពោធិ៍សាត់

គណៈកម្មការដេញថ្លៃភាសុីគ្រប់ប្រភេទសម្រាប់ធ្វើអាជីវកម្មឆ្នាំ២០២៥ ទូទាំងខេត្តពោធិ៍សាត់ មានកិត្តិយស សូមជម្រាបជូនដំណឹងដល់ប្រជាពលរដ្ឋកម្ពុជាទាំងពីរភេទដែលមានអាយុចាប់ពី ១៨ឆ្នាំឡើងទៅ (លើកលែងតែមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ សិស្ស និស្សិត) ឱ្យបានជ្រាបថា នៅថ្ងៃទី៣ ខែធ្នូ គ.ស. ២០២៤ ចាប់ពីម៉ោង ៨:៣០ នាទីព្រឹក តទៅ នៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្តពោធិ៍សាត់ នឹងមានរៀបចំពិធីដេញថ្លៃជាសាធារណៈភាសុីគ្រប់ប្រភេទសម្រាប់ធ្វើអាជីវកម្មឆ្នាំ២០២៥ ទូទាំងខេត្តពោធិ៍សាត់ ដូចមានរាយលំអិតក្នុងតារាងខាងក្រោម៖

| ល.រ | មុខសញ្ញាភាសុី | ទីតាំងអាជីវកម្មភាសុី | | តម្លៃមូលដ្ឋាន (រៀល) | ផ្សេងៗ |
|---|---|---|---|---|---|
| | | ឃុំ-សង្កាត់ | ស្រុក-ក្រុង | | |
| **ក- ភាសុីផ្សារ** | | | | | |
| ១ | ថ្មីពោធិ៍សាត់ | ផ្ទះព្រៃ | ពោធិ៍សាត់ | ៨០.០០០.០០០ | |
| ២ | ក្រគរ | អន្លង់ត្នោត | ក្រគរ | ៤០.០០០.០០០ | |
| ៣ | កណ្តៀង-ក្បាលហុង | ស្វាយលួង-រាំល | កណ្តៀង | ៤.០០០.០០០ | |
| ៤ | ស្វាយដូនកែវ-អូរតាប៉ោង | ស្វាយដូនកែវ-អូរតាប៉ោង | បាកាន | ២.៥០០.០០០ | |
| ៥ | បំណក់ | ឈើតុំ | ក្រគរ | ២៨.០០០.០០០ | |
| ៦ | ប្រម៉ោយ(គួបចំណតរថយន្ត) | ប្រម៉ោយ | វាលវែង | ៨.០០០.០០០ | |
| ៧ | ផ្សារបឹងខ្នារ | បឹងខ្នារ | បាកាន | ១៥.០០០.០០០ | |
| ៨ | ផ្សារត្រពាំងជង | ត្រពាំងជង | បាកាន | ១១.០០០.០០០ | |
| **ខ- ភាសុីសត្តឃាតដ្ឋាន** | | | | | |
| ១ | ប្រម៉ោយ | ប្រម៉ោយ | វាលវែង | ១០.០០០.០០០ | |
| **គ- ភាសុីចំណត** | | | | | |
| ១ | ចំណតកំពង់លួង | កំពង់លួង | ក្រគរ | ១៥.០០០.០០០ | |
| ២ | ចំណតរថយន្តបាកាន | បឹងខ្នារ | បាកាន | ៧.០០០.០០០ | |

បញ្ជាក់ ៖ ការដេញថ្លៃភាសុីសត្តឃាតដ្ឋានសម្រាប់រយៈពេល ២ឆ្នាំម្តង។

**អាជីវករដែលដាក់ពាក្យសុំចូលដេញថ្លៃ ត្រូវបំពេញកាតព្វកិច្ចដូចខាងក្រោម ៖**

១- បង់ប្រាក់កក់បណ្ដោះអាសន្នចំនួន ២០ (ម្ភៃ) ភាគរយ នៃថ្លៃមូលដ្ឋាន ។ ការបង់ប្រាក់កក់ទីតាំងណា គឺអនុញ្ញាតឱ្យចូលរួមដេញថ្លៃតែទីតាំងនោះប៉ុណ្ណោះ ដោយមិនអនុញ្ញាតឱ្យចូលរួមដេញថ្លៃទីតាំងដទៃទៀតដែលអាជីវករមិនបានបង់ប្រាក់កក់នោះទេ។ ប្រាក់កក់បណ្ដោះអាសន្ន និងប្រាក់កក់ស្ថាពរ ត្រូវបង់នៅរតនាគារខេត្តពោធិ៍សាត់ ឬធនាគារឯកជនតាមការកំណត់របស់រដ្ឋជាប្រាក់រៀល ដោយបំពេញបែបបទនៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្តពោធិ៍សាត់។

២- ត្រូវមានធនធាន ឬអចលនវត្ថុធានាចំនួន ៥០ (ហាសិប) ភាគរយ នៃតម្លៃមូលដ្ឋាន។ ធនធាន ឬអចលនវត្ថុធានានេះជាកម្មសិទ្ធិរបស់អាជីវករផ្ទាល់ មិនអនុញ្ញាតឱ្យយកកម្មសិទ្ធិអ្នកដទៃមកជំនួសឡើយ ហើយត្រូវមានការវាយតម្លៃបញ្ជាក់ពីចៅសង្កាត់ ឬមេឃុំ និងត្រូវមានការទទួលស្គាល់ពីមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

៣- ប្រាក់កក់បណ្ដោះអាសន្ន ២០ (ម្ភៃ) ភាគរយ នៃតម្លៃមូលដ្ឋានរបស់អាជីវករនឹងត្រូវរឹបអូសជាប្រយោជន៍ថវិកាខេត្ត ប្រសិនបើអ្នកដាក់ពាក្យចូលរួមដេញថ្លៃ មិនបានចូលដេញថ្លៃដោយគ្មានមូលហេតុ ឬក្នុងមូលហេតុដែលមិនអាចទទួលយកបាន ឬក៏ប្រកែកពុំព្រមចូលដេញថ្លៃ។ ក្នុងករណីសាមីខ្លួនអវត្តមានដោយមូលហេតុចាំបាច់ណាមួយ ត្រូវធ្វើលិខិតប្រគល់សិទ្ធិឱ្យតំណាងរបស់ខ្លួនចូលរួមដេញថ្លៃជំនួសដោយមានការបញ្ជាក់ពីចៅសង្កាត់ ឬមេឃុំ ហើយលិខិតប្រគល់សិទ្ធិនេះ ត្រូវមានការឯកភាពយល់ព្រមពីគណៈកម្មការដេញថ្លៃ។

៤- ករណីអ្នកដាក់ពាក្យចូលរួមដេញថ្លៃនៅមានជំពាក់បំណុលរដ្ឋ មិនអនុញ្ញាតឱ្យដាក់ពាក្យចូលរួមដេញថ្លៃភាសីគ្រប់ប្រភេទឡើយ។

៥- ករណីអ្នកដាក់ពាក្យចូលរួមដេញថ្លៃ បានប្រព្រឹត្តល្មើសធ្ងន់ធ្ងរក្នុងសៀវភៅបន្ទុក និងកិច្ចសន្យា ព្រមទាំងមិនគោរពតាមការណែនាំរបស់រដ្ឋបាលខេត្ត មិនអនុញ្ញាតឱ្យដាក់ពាក្យចូលរួមដេញថ្លៃភាសីគ្រប់ប្រភេទឡើយ។

**អាជីវករដែលមានបំណងដាក់ពាក្យចូលរួមដេញថ្លៃ ត្រូវបំពេញសំណុំបែបបទដូចខាងក្រោម ៖**

| | |
|---|---|
| - ពាក្យសុំចូលដេញថ្លៃ (មានគំរូ) | ចំនួន ០២ ច្បាប់ |
| - រូបថត ៤ x ៦ | ចំនួន ០២ សន្លឹក |
| - អត្តសញ្ញាណប័ណ្ណ ឬប័ណ្ណគ្រួសារ ថតចម្លង | ចំនួន ០២ ច្បាប់ |
| - បង្កាន់ដៃបង់ប្រាក់កក់ធានាបណ្ដោះអាសន្ន ចេញដោយរតនាគារខេត្តពោធិ៍សាត់ ស្មើនឹង ២០% នៃតម្លៃមូលដ្ឋាន | ចំនួន ០១ ច្បាប់ |
| - ធនធានធានា ឬអចលនវត្ថុធានាដែលមានតម្លៃស្មើនឹង ៥០% នៃតម្លៃមូលដ្ឋាន ដោយមានការបញ្ជាក់ពីចៅសង្កាត់-មេឃុំ ហើយត្រូវមានការទទួលស្គាល់ពីមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដី និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ចំនួន ០១ ច្បាប់ |
| - កិច្ចសន្យាប្រគល់ប្រាក់កក់ធានាបណ្ដោះអាសន្នជូនរដ្ឋ | ចំនួន ០២ ច្បាប់ |
| - កិច្ចសន្យាប្រគល់ប្រាក់កក់ធានាស្ថាពរជូនរដ្ឋ | ចំនួន ០២ ច្បាប់ |
| - កិច្ចសន្យាស្ដីពីការប្រតិបត្តិតាមសៀវភៅបន្ទុក | ចំនួន ០២ ច្បាប់ |

អាជីវករអាចមកទំនាក់ទំនងសាកសួរព័ត៌មានបន្ថែម នៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្តពោធិ៍សាត់ រៀងរាល់ម៉ោងធ្វើការ ឬតាមរយៈទូរស័ព្ទលេខ ០៧៨ ៦៣៣ ៨៨៦/០៩៣ ៤១៩ ៩៩៤។

ពាក្យសុំចូលរួមដេញថ្លៃចាប់ទទួលពីថ្ងៃប្រកាសផ្សាយសេចក្តីជូនដំណឹងនេះ រហូតដល់ថ្ងៃទី២ ខែធ្នូ ឆ្នាំ២០២៤ វេលាម៉ោង ១៧:៣០ នាទី នៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្តពោធិ៍សាត់។

ថ្ងៃ សុក្រ ៨ កើត ខែ កត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ពោធិ៍សាត់ ថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ២០២៤

**ជ. អភិបាលខេត្ត**

**អភិបាលរង និងជាប្រធានគណៈកម្មការដេញថ្លៃ**

**តាស៊ីគ្រប់ប្រភេទ សម្រាប់ធ្វើអាជីវកម្មឆ្នាំ២០២៥**

**ទូទាំងខេត្តពោធិ៍សាត់**

**គិត សុផា**

**កន្លែងទទួល៖**

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រដ្ឋបាលខេត្តពោធិ៍សាត់

"ដើម្បីជូនជ្រាប"

- រដ្ឋបាលក្រុង-ស្រុក គ្រប់ស្រុក
- រដ្ឋបាលឃុំ-សង្កាត់ គ្រប់ឃុំ-សង្កាត់

"ដើម្បីផ្សព្វផ្សាយ"

- ឯកសារ-កាលប្បវត្តិ